**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ.....០៩៧/២២.ក. ស. ភ.

ថ្ងៃ ពុធ ៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព. ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបេក្ខជនឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សម្រាប់អាណត្តិទី៨ នៃក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តភ្នំពេញ

**កំពង់ផែស្វយ័តភ្នំពេញ** (**ក. ស. ភ.**) ជាសហគ្រាសសាធារណៈ មានទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។ ក. ស. ភ. ជាកំពង់ផែអន្តរជាតិតាមដងទន្លេ ដែលដើរតួនាទីជាប្រតិបត្តិករផែ និងអាជ្ញាធរផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក. ស. ភ. មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជនទាំងអស់ ឱ្យបានជ្រាបថា ក. ស. ភ. នឹងធ្វើការជ្រើសរើសបេក្ខជន-បេក្ខនារី ដែលមានបំណងឈរឈ្មោះជា អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ដើម្បីដាក់ជូនមហាសន្និបាតភាគហ៊ុនិកបោះឆ្នោតសម្រេចជ្រើសរើសជាសមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ. សម្រាប់អាណត្តិទី៨ (រយៈពេល ៣ ឆ្នាំ) ដែលគ្រោងនឹងប្រព្រឹត្តទៅនៅអំឡុងខែឧសភា ឆ្នាំ២០២២ ខាងមុខនេះ។

### ១. លក្ខខណ្ឌ និងគុណវុឌ្ឍិនៃការជ្រើសរើស

បេក្ខជន-បេក្ខនារី ដែលមានបំណងដាក់ពាក្យឈរឈ្មោះជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ត្រូវបំពេញលក្ខខណ្ឌ និងមានគុណវុឌ្ឍិ ដូចខាងក្រោម÷

#### ក. លក្ខខណ្ឌនៃការជ្រើសរើស

- ត្រូវមានអាយុចាប់ពី ៣៥ ឆ្នាំឡើងទៅ (គិតត្រឹមថ្ងៃដាក់ពាក្យ)
- ត្រូវកាន់កាប់មូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតរបស់ ក. ស. ភ. យ៉ាងតិចចំនួន ០,៣% នៃមូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតសរុបរបស់ ក. ស. ភ.
- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូលខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកគ្រប់គ្រង ឬផ្នែកគ្រប់គ្រងកំពង់ផែ ផ្នែកដឹកជញ្ជូន ឬផ្នែកភ័ស្តុភារកម្ម
- ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច៣ឆ្នាំ ផ្នែកសេដ្ឋកិច្ច ឬផ្នែកគ្រប់គ្រង ឬផ្នែកគ្រប់គ្រងកំពង់ផែ ផ្នែកដឹកជញ្ជូន ឬផ្នែកភ័ស្តុភារកម្ម
- ចំពោះបេក្ខជន ដែលជាជនបរទេស ត្រូវមានបទពិសោធន៍ការងារក្នុងប្រទេសកម្ពុជា យ៉ាងតិច ៦ ខែ (គិតត្រឹមថ្ងៃដាក់ពាក្យ)
- មិនដែលត្រូវបានផ្តន្ទាទោសជាបទវិន័យរដ្ឋបាល ដែលបញ្ជាក់ដោយអង្គភាពដែលខ្លួនបម្រើការងារ (ត្រូវប្រគល់លិខិតបញ្ជាក់ក្រោយពីត្រូវបានបោះឆ្នោតជ្រើសតាំង)

- មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួន ដែលបានប្រកាសដោយតុលាការ (ត្រូវប្រគល់លិខិតបញ្ជាក់ក្រោយពីត្រូវបានបោះឆ្នោតជ្រើសតាំង)
- មិនធ្លាប់ត្រូវបានដកហូតអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬត្រូវបានហាមឃាត់បំពេញតួនាទីជាអភិបាល ឬអ្នកគ្រប់គ្រងក្រុមហ៊ុន ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ
- ត្រូវមានលិខិតថ្កោលទោស ដែលបញ្ជាក់ថាមិនធ្លាប់មានទោសក្នុងបទមជ្ឈិម ឬបទឧក្រិដ្ឋ (ត្រូវប្រគល់លិខិតបញ្ជាក់ក្រោយពីត្រូវបានបោះឆ្នោតជ្រើសតាំង)។

### ខ. គុណវុឌ្ឍិរបស់បេក្ខជនឈរឈ្មោះ

- មាននីត្យានុកូលភាព ទេពកោសល្យ សមត្ថភាព និងសុចរិតភាព
- មានការប្តេជ្ញាចិត្តខ្ពស់ដើម្បីផលប្រយោជន៍របស់ ក. ស. ភ. និងភាគហ៊ុនិក
- មានពេលវេលា ថាមពល និងការគាំទ្រដើម្បីបំពេញគ្រប់ភារកិច្ច រួមមានការជួបប្រជុំ និងការចូលរួមសន្និសីទ
- មានលទ្ធភាពធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព
- មានលទ្ធភាពអាចធ្វើការប្រកបដោយប្រសិទ្ធភាព ឆ្ពោះទៅរកគោលដៅរួមរបស់ ក. ស. ភ. និងភាគហ៊ុនិក
- យល់អំពីតួនាទីរបស់ខ្លួនជាអភិបាលក្នុងធុរកិច្ច
- បង្ហាញភាពជាអ្នកដឹកនាំ
- មានលទ្ធភាពដើរតួនាទីយ៉ាងសកម្មនៅពេលដែល ក.ស.ភ. ជួបប្រទះស្ថានភាពវិកវរ។

## ២. ការទទួលខុសត្រូវរបស់បេក្ខជនដែលជាប់ឆ្នោតជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន

- ជាសមាជិកក្រុមប្រឹក្សាភិបាល
- ជាសមាជិកគណៈកម្មាធិការតែងតាំង និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាភិបាល
- ចូលរួមនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងមហាសន្និបាតភាគហ៊ុនិក
- អនុម័តលើគោលនយោបាយ និងនីតិវិធីអនុវត្តសម្រាប់ ក. ស. ភ.
- ចូលរួមចំណែក និងអនុម័តផែនការយុទ្ធសាស្រ្ត
- ធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ
- ធានាសាធនភាពហិរញ្ញវត្ថុរបស់ ក. ស. ភ. តាមរយៈការគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញវត្ថុបានត្រឹមត្រូវ
- ផ្តល់នូវភាពជាអ្នកដឹកនាំ ការគាំទ្រ និងការលើកទឹកចិត្តដល់និយោជិត
- ធានាថាក្រុមប្រឹក្សាភិបាលមានប្រសិទ្ធភាពក្នុងការដឹកនាំ ក. ស. ភ.
- ចូលរួមក្នុងការសម្រេចគោលដៅរបស់ ក. ស. ភ.
- ផ្តល់នូវទស្សនវិស័យស្តីពីប្រសិទ្ធភាព និងគណនេយ្យភាពចំពោះភាគហ៊ុនិក
- ការទទួលខុសត្រូវផ្សេងទៀត តាមការចាំបាច់។

## ៣. អត្ថប្រយោជន៍ដែលទទួលបាន

- ប្រាក់ឧបត្ថម្ភប្រចាំខែ
- ការឧបត្ថម្ភជូននូវប្រេងឥន្ទនៈប្រចាំខែ
- ប្រាក់ថ្លែងសរសើរប្រចាំឆ្នាំ

- ឧបត្ថម្ភសំលៀកបំពាក់ប្រចាំឆ្នាំ
- ប្រាក់ឧបត្ថម្ភផ្សេងៗទៀត នាឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ និងបុណ្យភ្ជុំបិណ្ឌ។

## ៤. សំណុំលិខិតក្នុងការដាក់ពាក្យឈរឈ្មោះ

| | |
|---|---|
| - ជីវប្រវត្តិសង្ខេប (CV) មានបិទរូបថត (៤x៦) | ចំនួន ១ ច្បាប់ |
| - លិខិតបង្ហាញចំណាប់អារម្មណ៍ (Cover Letter) | ចំនួន ១ ច្បាប់ |
| - សេចក្តីចម្លងសញ្ញាបត្រដែលមានការបញ្ជាក់ត្រឹមត្រូវ | ចំនួន ១ ច្បាប់ |
| - លិខិតបញ្ជាក់ការងារ (Recommendation Letter) | ចំនួន ១ ច្បាប់ |

- ឯកសារចាំបាច់ផ្សេងៗទៀត។

## ៥. ទីកន្លែង កាលបរិច្ឆេទ នៃការទទួលពាក្យ និងឈប់ទទួលពាក្យ

- **កាលបរិច្ឆេទចាប់ផ្តើមទទួលពាក្យ÷** *ចាប់ពីថ្ងៃទី......១......ខែ...មេសា...ឆ្នាំ២០២២* រៀងរាល់ម៉ោងធ្វើការ (ពេលព្រឹកចាប់ពីម៉ោង ៨:០០-១២:០០ នាទី និងពេលរសៀលចាប់ពីម៉ោង ១៣:៣០ នាទី-១៧:០០ នាទី)
- **កាលបរិច្ឆេទឈប់ទទួលពាក្យ÷** *នៅថ្ងៃទី ...២១... ខែ...មេសា...ឆ្នាំ២០២២* វេលាម៉ោង ១៧:០០ នាទី
- **ទីកន្លែងទំនាក់ទំនង និងទទួលពាក្យ÷**
  - នៅនាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស ជាន់ទី១ បន្ទប់លេខ ១១០ នៃទីស្នាក់ការកណ្តាល ក. ស. ភ. ដែលមានអាសយដ្ឋាន អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - ឬតាមរយៈសារអេឡិចត្រូនិក ÷ ppapmpwt@online.com.kh

សម្រាប់ព័ត៌មានលម្អិត សូមមកទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស ឬតាមរយៈលេខទូរសព្ទ (៨៥៥) ០១០ ៤៤៤ ៣៦៧, (៨៥៥) ០១០ ៤៤៤ ០៨២, (៨៥៥) ០១០ ៤៤៤ ០១៧។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទាំងអស់ទទួលជ្រាបជាព័ត៌មាន។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**ប្រធានអគ្គនាយក**

**ហ៊ី-ឫទ្ធី**

**ចម្លងជូន÷**
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា

*"ដើម្បីគោរពជូនជ្រាប"*
- ផ្សារមូលបត្រកម្ពុជា
- ក្រុមហ៊ុនមូលបត្រ

*"ដើម្បីផ្សព្វផ្សាយ"*
- ឯកសារកាលប្បវត្តិ